ទស្សនៈអ្នកនិពន្ធ

វ៉ុល២, លេខ២៣, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

# ភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរ តាមរយៈ ឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ"

អ៊ុន លាង *

ខ្ញុំនឹងចាប់ផ្តើមស្វែងរកប្រភពនៃភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរ តាមរយៈសំណួរ៖ តើឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ" ជាអ្នកណា? តើឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ" ដែលជាបុព្វបុរសខ្មែរយើងមានប្រភពមកពីណា? តើយើងអាចសិក្សាពីភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរ តាមរយៈចម្លើយចំពោះសំណួរទាំងនេះបានដែរ ឬទេ?

ចាប់តាំងពីសម័យប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ត្រូវបានគេស្គាល់ថាជាអាណាចក្រនគរភ្នំ ឬហ្វូណន និងក្រោយមកអាណាចក្រចេនឡា មុនពេលចក្រភពអង្គរ ត្រូវបានបង្កើតឡើង និងការបង្កើត/រកឃើញ ពាក្យកម្ពុជទេស/កម្វុជទេស សិលាចារិកបក្សីចាំក្រុង (K.២៨៦) និងសិលាចារិកស្តុកកក់ធំ (K.២៣៥)។ យើងធ្លាប់បានឮរឿងព្រេងមួយដែលនិទានថា ព្រះបាទ "កៅណ្ឌិន្យ" មកពីប្រទេសឥណ្ឌាបាននាំរាជបរិពារ និងសំពៅមកនគរភ្នំ ហើយក៏បានច្បាំងជាមួយទ័ពម្ចាស់ស្រុករបស់ព្រះនាង "សោមា" បានទទួលជ័យជំនះ រួចរៀបអភិសេកជាមួយព្រះនាង រៀបចំទឹកដីនគរភ្នំឱ្យកើតជាអាណាអាចក្របែបឥណ្ឌា។ ក្រោយមក នគរភ្នំបានក្លាយជាចេនឡា និងបានវិវត្តមកជាប្រទេសកម្ពុជា ដែលក្លាយមកពីពាក្យ កម្ពុជៈ។ យើងក៏ធ្លាប់បានឮរឿងព្រេងនិទានមួយទៀតតាមសិលាចារិកបក្សីចាំក្រុង ដែលបានរៀបរាប់អំពីបុព្វការីជនដំបូងបង្អស់នៃជនជាតិខ្មែរ ថាមានតំណពូជពង្សមកពីឥសីមួយអង្គព្រះនាម "កម្ពុ" ដែលបង្កើតដោយឯកឯង (ស្វាយម្ភូ)។ ក្រោយមក ឥសីនោះបានរៀបការជាមួយទេពកញ្ញាឈ្មោះ "មេរា" រួចបង្កើតជាកូនជាចៅតរៀងមក ហើយដាក់ឈ្មោះប្រទេសថា "កម្ពុជា"។

ប៉ុន្តែអ្វីដែលសំខាន់បំផុត តើព្រះបាទ "កៅណ្ឌិន្យ" និង ឥសី "កម្ពុ" មកពីទីណាពិតប្រាកដ? នៅពេលដែលយើងជឿថាមនុស្សដែលកើតនៅក្នុងប្រទេសកម្ពុជាជាកូនចៅ ឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ" ដែលជាបុព្វបុរសរបស់យើងមកពីប្រទេសឥណ្ឌា ហើយយើងហៅប្រទេសរបស់យើងថាប្រទេសកម្ពុជា នោះនាំឱ្យយើងនឹកដល់ក្រុមកុលសម្ព័ន្ធមួយ ឬអាណាចក្រមួយនៅប្រទេសឥណ្ឌាភាគពាយព្យ ដែលមានឈ្មោះថា "កម្ពោជ" (Kambojas)។ មានការអះអាងខ្លះៗថា ពាក្យ "កម្ពុជា" នេះ ទំនងយកពីឈ្មោះក្រុមកុលសម្ព័ន្ធ ឬអាណាចក្រកម្ពោជនេះ ដែលឈ្មោះនេះពិតជាមាននៅក្នុងគម្ពីរនានារបស់ពុទ្ធសាសនា និងហិណ្ឌូសាសនាទាំងនៅក្នុងប្រទេសខ្មែរ និងនៅក្រៅប្រទេសខ្មែរ។ សំណួរមួយដែលយើងអាចចោទសួរឡើងនោះគឺថា តើអាចទេដែលក្រុមកុលសម្ព័ន្ធកម្ពោជ (Kambojas) ពិតជាបានធ្វើដំណើរមកដល់ទឹកដីខ្មែរ នគរភ្នំ/ហ្វូណន ឬចេនឡា រួចបង្កើតជាចក្រភពខ្មែរ ឬកម្ពុជទេសរបស់យើង?

---

*បណ្ឌិត អ៊ុន លាង គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

តើជនជាតិកម្ពោជជាអ្នកណា? ជនជាតិកម្ពោជ ជាកុលសម្ព័ន្ធមួយរស់នៅតំបន់ឥណ្ឌាភាគពាយព្យ ក្នុងយុគសម័យដែក។ ហេតុអ្វីបានជាពួកគេអាចធ្វើដំណើរមកដល់ទឹកដីខ្មែរ? យោងតាមគេហទំព័ររបស់សមាគមកម្ពោជ៖ វេទិកាសាកលសម្រាប់សហគមន៍កម្ពោជ បានសរសេរថា ប្រឈមនឹងការឈ្លានពានរបស់ពួកឥណ្ឌូស៊ីឡៀន (Indo-Scythian) មកលើប្រទេសឥណ្ឌាក្នុងអំឡុងពេលមុនការបង្កើតចក្រភពគូសាណៈ (Kushana) ជនជាតិកម្ពោជបានធ្វើចំណាកស្រុកមកកាន់តំបន់ ប៉ែងហ្គល ស្រីលង្កា និងកម្ពុជាក្នុងចន្លោះ សតវត្សរ៍ទី២មុនគ.ស និងសតវត្សរ៍ទី៥នៃគ.ស[1]។ ពេលវេលាហាក់ដូចជាជំណាលគ្នាណាស់នឹងការបង្កើតរដ្ឋដំបូងនៅសម័យនគរភ្នំ/ហ្វូណន និងក្រោយមកទៀតការបង្កើតរដ្ឋចេនឡា។ មានការសិក្សាជាច្រើន ពិតជាបានគាំទ្រថា ជនជាតិកម្ពោជ បានមកដល់ទឹកដីឥណ្ឌូចិនមែន ទោះបីជាពុំទាន់មានការយល់ស្របគ្នាថា មកតាមរយៈផ្លូវគោកឆ្លងតាមទីបេ ឬផ្លូវសមុទ្រក៏ដោយ[2]។

ប៉ុន្តែ មកតាមប្រភពណាមិនមែនជាសំណួរ និងចម្លើយសំខាន់របស់ខ្ញុំដែលមិនមែនជាប្រវត្តិវិទូ និងបុរាណវិទូនោះទេ។ ខ្ញុំគិតថា នេះជាកាតព្វកិច្ចរបស់ប្រវត្តិវិទូ និងបុរាណវិទូ។ អ្វីដែលខ្ញុំប៉ុនប៉ងបញ្ជាក់ នោះគឺការដកស្រង់ភស្តុតាងសម្មតិកម្មប្រវត្តិសាស្ត្រ[3]ថា ជនជាតិកម្ពោជប្រហែលពិតជាបានមកដល់ទឹកដីខ្មែរមែន ហើយនេះគឺគ្រាន់តែជាសារតាមួយសម្រាប់ចំណាប់អារម្មណ៍ដ៏ធំជាងនេះរបស់ខ្ញុំ នោះគឺការសិក្សាអំពីភាពជាខ្មែរ និងថាតើវាអាចមានទស្សនវិជ្ជាខ្មែរដែរឬទេ បន្ទាប់ពីពួកគេបានមកដល់ និងបង្កើតបានជាចក្រភពអង្គរមួយដែលមានអរិយធម៌ខ្ពង់ខ្ពស់ និងចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ដីគោក? ហើយប្រសិនបើមានភាពជាខ្មែរ និងទស្សនវិជ្ជាខ្មែរនៅក្នុងសម័យកាលនោះមែន តើវាមានជានណាខ្លះ ដែលបានបន្សល់ទុកក្នុងពេលបច្ចុប្បន្ន ឬតើភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរនេះ អាចនៅមានតម្លៃសម្រាប់សង្គមសហសម័យកម្ពុជាដែរឬទេ?

ខ្ញុំនឹងស្នើឱ្យមានសិក្សាអំពីប្រភពភាពជាខ្មែរតាមរយៈពង្សាវតារបស់កុលសម្ព័ន្ធកម្ពោជ និងប្រព័ន្ធវណ្ណៈហិណ្ឌូនៅប្រទេសឥណ្ឌា ប្រសិនបើសម្មតិកម្មប្រវត្តិសាស្ត្រដែលថាជនជាតិកម្ពោជ ពិតជាបានមកដល់ទឹកដីខ្មែរមែន។ តាមគេហទំព័ររបស់សមាគមកម្ពោជ៖ វេទិកាសាកលសម្រាប់សហគមន៍កម្ពោជបានសរសេរថា កម្ពោជ គឺជាមនុស្សដែលមានភាពអស្ចារ្យខាងសិល្បៈ និងវិទ្យាសាស្ត្រ ជាអ្នកប្រាជ្ញ និងព្រះរាជគ្រូនៃគម្ពីរវេទ។ នៅក្នុងអក្សរសិល្ប៍ឥណ្ឌាបុរាណ ពិតជាបានពិពណ៌នាពីភាពខុសគ្នារវាង ក្រុមកម្ពោជជាវណ្ណៈព្រាហ្មណ៍ និងក្រុមកម្ពោជជាវណ្ណៈក្សត្រមែន។ ជនជាតិកម្ពោជ គឺមានសារជាតិជាវណ្ណៈក្សត្រ/អ្នកធ្វើសង្គ្រាម (ដឹកនាំ ការពារសង្គម ចាត់ចែងការងាររដ្ឋបាលក្នុងប្រទេស) និងវណ្ណៈព្រាហ្មណ៍ (បញ្ញវន្ត បង្កើតវប្បធម៌ ពុទ្ធិ ក្រមសីលធម៌ និងការពារយុត្តិធម៌)។ ទាំងនេះប្រហែលជាអាចបញ្ជាក់បានថា ឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ" ប្រហែលជាបានមកដល់នគរភ្នំ/ហ្វូណន ឬចេនឡាមែន ទោះបីជាក្នុងពេលតែមួយ ឬក្នុងពេលខុសគ្នាក៏ដោយ។ និយាយម្យ៉ាងវិញទៀត តាមទ្រឹស្តីវណ្ណៈនៃសាសនាហិណ្ឌូ ព្រះបាទ "កៅណ្ឌិន្យ" គឺជាអ្នកធ្វើសង្គ្រាមដ៏អស្ចារ្យស្ថិតក្នុងវណ្ណៈក្សត្រ ហេតុនេះក្លាយជាព្រះមហាក្សត្រក្រោយឈ្នះសង្គ្រាម ដឹកនាំអាណាចក្រជាមួយក្រុមរាជបរិពាររបស់ព្រះអង្គ ហើយឥសី "កម្ពុ" ស្ថិតក្នុងវណ្ណៈ

---

[1] ប្រសិនបើមិនមានការដាក់ប្រភពណាផ្សេងទេ រាល់ការសន្និដ្ឋាន និងសម្រង់ទាំងអស់ជាការសង្ខេបដកស្រង់ចេញពី https://www.kambojsociety.com/post/who-are-kamboj ចូលមើលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០។

[2] ប៉ុន្តែជាការសន្និដ្ឋានដែលអាចទៅរួចទាំងពីរតាមរឿងនិទានរបស់ខ្មែរ។ តាមផ្លូវគោក ប្រហែល ឥសី "កម្ពុ"។ ស្ថានភាពដែលសិលាចារិកមាននៅតំបន់អង្គរឆ្ងាយពីនគរភ្នំ/ហ្វូណនដែលនៅកៀកសមុទ្រ។ តាមផ្លូវសមុទ្រ ព្រះបាទ "កៅណ្ឌិន្យ" ដែលតាមរឿងព្រេងនិទានបានចេញសំពៅមកពីឥណ្ឌា។

[3] សម្មតិកម្មដែលទាមទារឱ្យមានការសិក្សាស៊ីជម្រៅ និងច្បាស់លាស់តាមវិធីសាស្ត្រនៃមុខវិជ្ជានានាដូចជា បុរាណវិទ្យា ប្រវត្តិវិទ្យា នរវិទ្យាវប្បធម៌ និងភាសាវិទ្យា។ល។

ព្រាហ្មណ៍ គឺជាអ្នកប្រាជ្ញ ជាបញ្ញវន្ត ជាព្រះរាជគ្រូ ពេលបានរៀបការជាមួយទេពកញ្ញា "មេរា" បានជួយរៀបចំបង្កើតវប្បធម៌ក្នុងអាណាចក្រថ្មីនេះ[4]។ ការសន្មតនេះ គឺយោងតាមការសិក្សាពីពង្សាវតារបស់ព្រាហ្មណ៍នៅក្នុងគម្ពីរវេទ និងអក្សរសិល្ប៍ឥណ្ឌាបុរាណដែលបាននិយាយពីព្រាហ្មណ៍ និងក្សត្រត្រកូលកម្ពោជ និងកៅណ្ឌិន្យ។

ខ្ញុំបញ្ចប់អត្ថបទនេះជាមួយសម្រង់ឃ្លាមួយនៅក្នុងគម្ពីរឥណ្ឌាបុរាណ "ព្រាហ្មណ៍កម្ពោជមានទំនាក់ទំនងជិតស្និទ្ធទាំងក្នុងជីវិតសង្គម និងវប្បធម៌ជាមួយគ្រួសារព្រាហ្មណ៍ វ៉ាស៊ីស៊ីថៈ (Vasishtha) ដែលត្រូវបានចាត់ទុកថា ជាវីរបុរសខាងវប្បធម៌នៅក្នុងអរិយធម៌វេទនៅប្រទេសឥណ្ឌា"។ កាតព្វកិច្ចបន្ត គឺត្រូវសិក្សាអំពីអក្សរសាស្ត្រ និងអក្សរសិល្ប៍របស់ក្រុមកុលសម្ព័ន្ធកម្ពោជ ដែលបាននាំមកប្រទេសកម្ពុជា គំនិត/ទស្សនៈដែលជាប្រភពអំពីភាពជាខ្មែរ ឬអាចថាជាទស្សនវិជ្ជាខ្មែរ[5]។ នេះនឹងអនុញ្ញាតឱ្យយើងមានលទ្ធភាពស្វែងរកដានខ្លះៗ ដែលបានបន្សល់ទុកក្នុងពេលបច្ចុប្បន្ន ហើយថាតើភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរនេះ អាចនៅមានតម្លៃសម្រាប់សង្គមសហសម័យកម្ពុជាដែរ ឬទេ ?

ការណ៍នេះមិនមែនមានន័យថា យើងបំភ្លេចគំនិត/ទស្សនៈទេពកញ្ញា "មេរា" និងព្រះនាង "សោមា" នោះទេ។ មានការសិក្សាខ្លះៗអំពីគំនិតនេះដែរ ដូចជា លោក ងួន ញ៉ិល បានសិក្សាអំពីព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ និងអ្នកសិក្សាទាំងខ្មែរ និងទាំងបរទេសដែលកំពុងពិភាក្សា ថាតើកម្ពុជាពិតជាមានរបបមាតាធិបតេយ្យ ឬគ្រាន់តែជាការប្រតិបត្តិយកលំនាំតាមខាងម្ដាយ ? ថាតើព្រលឹងមាតាធិបតេយ្យ ឬការប្រតិបត្តិយកលំនាំតាមខាងម្ដាយពិតជាមានវត្តមានក្នុងការចាត់ចែងរដ្ឋ/សង្គម ឬគ្រាន់តែជាការប្រតិបត្តិក្នុងជីវភាពប្រចាំថ្ងៃក្នុងស្រទាប់មហាជនទូទៅ ? បញ្ហាដែលពិតជាទាមទារឱ្យមានការសិក្សាវែកញែក ដើម្បីស្វែងរកមរតកគំនិត/ទស្សនៈទាំងនេះនៅក្នុងសង្គមសហសម័យកម្ពុជា។ ប៉ុន្តែ នេះជាអាទិភាពបន្ទាប់។

អាទិភាពទីមួយសម្រាប់ខ្ញុំ គឺការសិក្សាគំនិត/ទស្សនៈកុលសម្ព័ន្ធកម្ពោជដែលអាចជាប្រភពអំពីភាពជាខ្មែរ ឬអាចថាជាទស្សនវិជ្ជាខ្មែរ។ នេះមិនមែនពីព្រោះតែកន្លងមក បញ្ហានេះត្រូវបានគេបំភ្លេចចោលនោះទេ បញ្ហាសំខាន់បំផុតនោះ គឺស្វែងរកសិល្បៈនៃការដឹកនាំ និងចាត់ចែងរដ្ឋ/សង្គមដែលនាំឱ្យកម្ពុជាក្នុងពេលមួយឈានដល់ភាពកំពូលខាងអរិយធម៌[6]។

យើងប្រហែលជាអាចរៀនសូត្របានខ្លះ ពីសិល្បៈនៃការដឹកនាំ និងចាត់ចែងរដ្ឋ/សង្គមនាពេលនោះ និងចោទសួរថាតើបទពិសោធន៍ទាំងនោះ អាចណែនាំយើងក្នុងការដោះស្រាយបញ្ហានៅកម្ពុជានាសហសម័យបានដែរ ឬទេ ?

**អ្នកនិពន្ធជ្រើសយកការប្រើនិទ្ទេសជើងទំព័រសម្រាប់ឯកសារយោង។*

[4] រឿងនិទានទាំងពីររបស់ខ្មែរអំពី ឥសី "កម្ពុ" និងព្រះបាទ "កៅណ្ឌិន្យ" ហាក់ដូចជាឆ្លុះបញ្ចាំងអំពីប្រព័ន្ធវណ្ណៈនៃសាសនាហិណ្ឌូ។

[5] ទោះបីជាមិនមានការសិក្សាអំពីអក្សរសាស្ត្រ និងអក្សរសិល្ប៍របស់ក្រុមកុលសម្ព័ន្ធកម្ពោជ ការសិក្សាតាមរបៀបមួយទៀតក៏អាចនាំយើងទៅស្វែងរកប្រភពនៃភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរបានដែរ នោះគឺការសិក្សាអំពីឈ្មោះអ្នកប្រាជ្ញ និងឈ្មោះគម្ពីរ/ក្បួនខ្នាតដែលអ្នកប្រាជ្ញទាំងនោះចេះដឹងតាមសិលាចារិកខ្មែរដែលបានរកឃើញកន្លងមក។ យើងអាចរកឃើញខ្លះៗតាមនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោកស្រី ឆោម គន្ធា ដែលបច្ចុប្បន្នកំពុងធ្វើការនៅអាជ្ញាធរជាតិអប្សរា។ ការបូកបញ្ចូលគ្នារវាងការសិក្សាទាំងពីរបែបនេះ រឹតតែបន្ថែមសុពលភាពនៃប្រភព និងសុក្រឹតភាពនៃភាពជាខ្មែរ ឬទស្សនវិជ្ជាខ្មែរ ប្រសិនបើអក្សរសាស្ត្រ និងអក្សរសិល្ប៍ និងគម្ពីរ/ក្បួនខ្នាតទាំងនេះស៊ីចង្វាក់គ្នា។

[6] កន្លងមក ការសិក្សាអំពីគំនិតទាំងនេះ ភាគច្រើនបំផុតចេញពីអ្នកសិក្សាបរទេស។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center